ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

លេខ: ................អសជ/ .....

# របាយការណ៍សវនកម្មលើ កិច្ចប្រតិបត្តិការ ស្តីពីការគ្រប់គ្រងសេវាប្រមូលសំរាម នៅក្រុងកំពង់ចាម ខេត្តកំពង់ចាម

## ការិយបរិច្ឆេទ ២០២៣

អគារលេខ ៥ ផ្លូវឌួងងៀប៣ ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ
# 5, St. Duong Ngeab 3, Sangkat Tekthla, Khan Sensok, Phnom Penh, CAMBODIA

Tel:(855-23) 885 900, (855-12) 737 622 Fax: (855-023) 885 900

E-mail: naakh@naa.gov.kh website: www.naa.gov.kh

# របាយការណ៍សវនកម្មលើ
# កិច្ចប្រតិបត្តិការស្ដីពីការគ្រប់គ្រងសេវាប្រមូលសំរាម
# នៅក្រុងកំពង់ចាម ខេត្តកំពង់ចាមសម្រាប់ការិយបរិច្ឆេទ២០២៣

## របាយការណ៍សង្ខេប

អនុលោមតាមមាត្រា២ មាត្រា៣ និងមាត្រា៩នៃច្បាប់ស្ដីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មលើបណ្ដាក្រសួង ស្ថាប័ន និងរាជធានី ខេត្ត។ អាជ្ញាធរសវនកម្មជាតិបានជ្រើសរើសប្រធានបទស្ដីពីការគ្រប់គ្រងសេវាប្រមូលសំរាមនៅក្រុងកំពង់ចាម ខេត្តកំពង់ចាមសម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ ដើម្បីធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ ក្នុងគោលបំណងវាយតម្លៃអំពីភាពសន្សំសំចៃ ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងសេវាប្រមូលសំរាម ព្រមទាំងរួមចំណែកដល់ការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងធ្វើរបាយការណ៍ជូនទៅរដ្ឋសភា ព្រឹទ្ធសភា និងផ្ដល់ព័ត៌មានដល់រាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធ។

ឆ្លងតាមការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការស្ដីពីការគ្រប់គ្រងសេវាប្រមូលសំរាមនៅក្រុងកំពង់ចាម សម្រាប់ការិយបរិច្ឆេទ២០២៣ និងឆ្នាំពាក់ព័ន្ធ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រដ្ឋបាលក្រុងកំពង់ចាមបានខិតខំប្រឹងប្រែងអនុវត្តការងារគ្រប់គ្រងសេវាប្រមូលសំរាម និងលិខិតបទដ្ឋានគតិយុត្តនានាបានល្អ។ ទន្ទឹមនឹងនេះ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការគ្រប់គ្រងសេវាប្រមូលសំរាមនៅក្រុងកំពង់ចាមនៅមានចំណុចខ្វះខាតមួយចំនួន ដូចខាងក្រោម៖

១. កង្វះខាតមធ្យោបាយក្នុងការដឹកជញ្ជូនសំរាមតាមផ្លូវតូចចង្អៀត

២. កង្វះខាតប្រព័ន្ធតាមដានរថយន្តរបស់ក្រុមហ៊ុនប្រមូលសំរាម

៣. ក្រុមហ៊ុនស៊ីនទ្រីប្រមូលសំរាមតាមខ្នងផ្ទះប្រជាពលរដ្ឋយកមកស្តុកទុកនៅសាខារបស់ក្រុមហ៊ុន

៤. ទីលានទុកដាក់សំរាមរបស់ក្រុមហ៊ុនស៊ីនទ្រីនៅពុំទាន់មានលក្ខណៈត្រឹមត្រូវតាមស្តង់ដារ

៥. ការដុតសំរាមចោលនៅទីលានទុកដាក់សំរាមរបស់ក្រុមហ៊ុនស៊ីនទ្រី។

ផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសូមផ្ដល់អនុសាសន៍មួយចំនួន ដូចខាងក្រោម៖

១. រដ្ឋបាលក្រុងកំពង់ចាម គួរណែនាំជំរុញឱ្យក្រុមហ៊ុនស៊ីនទ្រីមានមធ្យោបាយគ្រប់គ្រាន់ក្នុងការដឹកជញ្ជូនសំរាមតាមផ្លូវតូចចង្អៀត។

២. រដ្ឋបាលក្រុងកំពង់ចាម គួរធ្វើការតាមដានរថយន្តប្រមូលសំរាមឱ្យបានម៉ត់ចត់ត្រឹមត្រូវ។

៣. រដ្ឋបាលក្រុងកំពង់ចាម គួរតែជំរុញឱ្យក្រុមហ៊ុនស៊ីនទ្រីបញ្ឈប់ការប្រមូលសំរាមយកមកស្តុកទុកនៅសាខារបស់ខ្លួន ដែលប៉ះពាល់ដល់បរិស្ថាន និងអនាម័យ។

៤. រដ្ឋបាលក្រុងកំពង់ចាម គួរចុះពិនិត្យទីលានទុកដាក់សំរាមរបស់ក្រុមហ៊ុនស៊ីនទ្រីជាប្រចាំ ឱ្យអនុវត្តតាមគោលការណ៍បរិស្ថាន។៚

៥. រដ្ឋបាលក្រុងកំពង់ចាម គួរណែនាំដល់ក្រុមហ៊ុនស៊ីនទ្រីបញ្ឈប់ការដុតសំរាមចោលនៅទីលានទុកដាក់សំរាមរបស់ខ្លួន។